# ទិវាជាតិសុខភាពមាតា ទារក និងកុមារ

## ប្រធានបទ៖ ការពង្រឹងសេវាថែទាំសុខភាពមាតា ទារក និងកុមារ ដើម្បីសម្រេចបាននូវគោលដៅគ្របដណ្តប់សុខភាពជាសកល

# សីលធម៌ក្នុងការអនុវត្តន៍វិជ្ជាជីវៈសុខាភិបាល

ថ្ងៃពុធ ១២កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
សណ្ឋាគារភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤

លោកស្រី ប្រាក់ ម៉ានីឡា អនុប្រធានគម្រោង USAID-EQHA II/FHI360

# ទិដ្ឋភាពទូទៅនៃមេរៀន

សេចក្តីផ្តើម

អ្វីទៅជាសីលធម៌?

គោលការណ៍សីលធម៌សម្រាប់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល

បញ្ហាឥរិយាបទសីលធម៌ដែលជួបញឹកញាប់

កត្តាជះឥទ្ធិពលលើឥរិយាបទប្រកបដោយសីលធម៌នៅក្នុងការអនុវត្តការងាររបស់បុគ្គលិកសុខាភិបាល

ឧទាហរណ៍នៃឯកសារមួយចំនួនជាមគ្គុទេសន៍សម្រាប់ជម្រុញឥរិយាបទសីលធម៌នៃអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលនៅកម្ពុជា

តើយើងពង្រឹងឥរិយាបទសីលធម៌បានយ៉ាងដូចម្តេច?

USAID FROM THE AMERICAN PEOPLE fhi360

# សេចក្ដីផ្ដើម

នៅក្នុងប្រទេសកម្ពុជាមានគិលានុបដ្ឋាក/ឆ្មបប្រមាណជា 60% នៃអ្នកប្រកបវិជ្ជាជីវៈទាំងអស់ក្នុងវិស័យសុខាភិបាល។

អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់គុណភាព សុវត្ថិភាព និងការថែទាំដែលផ្ដោតទៅលើអ្នកជំងឺ ឬអតិថិជនទាំងសេវាសាធារណៈ និងឯកជន។

អ្នកជំងឺ និងអតិថិជនពឹងផ្អែកទៅលើការផ្ដល់សេវាប្រកបដោយមេត្តាធម៌ និងការយកចិត្តទុកដាក់ពីអ្នកផ្ដល់សេវាដែលគួរតែប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍សីលធម៌។

ទំនាក់ទំនងប្រកបដោយទំនុកចិត្តរវាងអ្នកជំងឺ និងអ្នកវិជ្ជាជីវៈសុខាភិបាលជាកត្តារួមចំណែកដល់ការលើកកម្ពស់សីលធម៌ និងវិជ្ជាជីវៈនិយម។

# អ្វីទៅជាសីលធម៌ (Ethics)?

- Ethics provides a broader moral framework.
- Ethics is the application of ethical rules and values to human activities.
- Healthcare workers must possess not only the necessary skills and knowledge but also be aware of the ethical and legal responsibilities that come with standard practices.
- Clinical ethics has been founded on the framework of 4 ethical principles: **autonomy, beneficence, non-maleficence, and justice.**
- It deals with rights, responsibilities, language use, and the overall concept of living an ethical life.

# គោលការណ៍សីលធម៌សម្រាប់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល

គោលការណ៍សីលធម៌សំខាន់ៗទាំងបួនជាមគ្គុទេសន៍សម្រាប់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលជួបប្រទះបញ្ហាសីលធម៌ (ethical dilemmas) នៅពេលអនុវត្តការងារ ដែលអាចធ្វើការសម្រេចចិត្តដើម្បីលើកកម្ពស់គុណភាពថែទាំអ្នកជំងឺ។

| | |
|---|---|
| **ស្វ័យភាព (Autonomy)** | **អត្ថប្រយោជន៍ (Beneficence)** |
| **ភាពមិនផ្តល់គ្រោះថ្នាក់ (Non-maleficence)** | **យុត្តិធម៌ (Justice)** |

**អ្នកជំងឺ**

USAID FROM THE AMERICAN PEOPLE

fhi360

# គោលការណ៍សីលធម៌ (Ethical Principles)

ស្វ័យភាព៖ ទទួលស្គាល់សិទ្ធិរបស់អ្នកជំងឺ/អតិថិជនក្នុងការសម្រេចចិត្តដោយខ្លួនឯងអំពីសុខភាពដោយផ្អែកលើសាសនា/ទំនៀមទំលាប់ និងគុណតម្លៃរបស់ពួកគាត់។

អត្ថប្រយោជន៍៖ ធ្វើត្រូវ ឬធ្វើល្អ ដែលមានន័យថា តម្រូវឱ្យយើងតែងតែប្រព្រឹត្តដោយគិតពីផលប្រយោជន៍អ្នកជំងឺជាធំ។

យុត្តិធម៌៖ សង្កត់ធ្ងន់ទៅលើសារសំខាន់នៃការថែទាំ/ព្យាបាលអ្នកជំងឺប្រកបដោយយុត្តិធម៌

ភាពមិនផ្តល់គ្រោះថ្នាក់៖ ប្រព្រឹត្តដោយមិនបង្កគ្រោះថ្នាក់ដែលតម្រូវឱ្យយើងជ្រើសរើសនូវអន្តរាគមន៍ដែលមានប្រយោជន៍ មិនបង្កគ្រោះថ្នាក់ដល់អ្នកជំងឺ។

USAID FROM THE AMERICAN PEOPLE fhi360

# បញ្ហាសីលធម៌ ( Ethical dilemma ) ក្នុងការអនុវត្តវិជ្ជាជីវៈ

- គឺជាស្ថានភាពមួយដែលយើងត្រូវតែសម្រេចចិត្តរវាងគុណតម្លៃ និងការជ្រើសរើស មិនថានឹងមានរឿងអ្វីកើតឡើងនោះទេ សុទ្ធតែមានផលវិបាក។
- បញ្ហាសីលធម៌អាចផ្ទុយជាមួយនឹងគុណតម្លៃផ្ទាល់ខ្លួនរបស់យើង ឬក្រមសីលធម៌វិជ្ជាជីវៈ។
- មូលហេតុមួយចំនួនដែលអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលប្រឈមនឹងបញ្ហាសីលធម៌៖
  - *អ្នកជំងឺ ឬក្រុមគ្រួសាររបស់ពួកគេត្រូវតែធ្វើការសម្រេចចិត្តអំពីជីវិត ឬមរណភាព*
  - *អ្នកជំងឺបដិសេធន៍ការព្យាបាល*
  - *កិច្ចការថែទាំអាចផ្ទុយនឹងជំនឿសាសនា ឬវប្បធម៌*

USAID FROM THE AMERICAN PEOPLE fhi360

# បញ្ហាឥរិយាបទសីលធម៌ដែលជួបញឹកញាប់នៅជុំវិញពិភពលោក

- ការអនុវត្តក្រៅដែនកំណត់វិជ្ជាជីវៈ
- ការអនុវត្តដោយឯករាជ្យដែលមិនអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិ និយាម គោលនយោបាយ និងគោលការណ៍ណែនាំនានា
- បែកធ្លាយការសម្ងាត់របស់អ្នកជំងឺ
- កំណត់ត្រា ឬរបាយការណ៍ក្លែងបន្លំ
- ធ្វើឱ្យបុគ្គលិក/អ្នកជំងឺមានអារម្មណ៍ថាត្រូវបានបំភ័យ ឬមិនស្វាគមន៍

ចុះនៅក្នុងប្រទេសកម្ពុជាវិញ?

# កត្តាជះឥទ្ធិពលលើឥរិយាបទប្រកបដោយសីលធម៌នៅក្នុងការអនុវត្តការងារក្នុងមូលដ្ឋានសុខាភិបាល

The public has become increasingly concerned about healthcare workers' ethical behavior. This is frequently manifested as complaints about unethical behavior and an increase in the use of legal action against healthcare providers in Ethiopia.

Based on a study published by the journal BMC Medical Ethics "Clinical ethical practice and associated factors in healthcare facilities in Ethiopia" in 2022, found that **compassionate leadership**, **positive attitudes** and **enhanced the knowledge** of health professionals. Additionally, digitalization, intersectoral collaboration, and institutionalization are important for promoting clinical ethical practice.

# ឧទាហរណ៍នៃឯកសារមួយចំនួនជាមគ្គុទេសន៍សម្រាប់ជម្រុញ ឥរិយាបទសីលធម៌នៃអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលនៅកម្ពុជា

- កម្មវិធីសិក្សាមុនពេលបម្រើការងារ
- ប្រកាសស្តីពីការដាក់ឱ្យអនុវត្តនូវផែនកំណត់វិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- និយាមវិជ្ជាជីវៈនៃការអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- អនុក្រិត្យស្តីពីក្រមសីលធម៌
- សៀវភៅស្តីពីស្តង់ដារនៃការទទួលស្គាល់គុណភាពសេវាមន្ទីរពេទ្យនៃព្រះរាជាណាចក្រកម្ពុជា(MOH, 2022)
- សៀវភៅស្តីពីស្តង់ដារនៃការទទួលស្គាល់គុណភាពមណ្ឌលសុខភាពនៃព្រះរាជាណាចក្រកម្ពុជា (MOH, 2022)

USAID FROM THE AMERICAN PEOPLE fhi360

# ឯកសារមួយចំនួនណែនាំឥរិយាបទសីលធម៌ គិលានុបដ្ឋាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

សៀវភៅស្តីពី
ស្តង់ដារនៃការទទួលស្គាល់គុណភាពសេវាមន្ទីរពេទ្យ
នៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

សៀវភៅស្តីពី
ស្តង់ដារនៃការទទួលស្គាល់គុណភាពសេវាមណ្ឌលសុខភាព
នៃព្រះរាជាណាចក្រកម្ពុជា

បោះពុម្ពលើកទី១
ឆ្នាំ ២០២២

USAID FROM THE AMERICAN PEOPLE
fhi360

# តើយើងពង្រឹងឥរិយាបទសីលធម៌នៃការអនុវត្តការថែទាំនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយរបៀបណា?

តាមរយៈយន្តការទទួលគុណភាពសុខាភិបាលសម្រាប់មូលដ្ឋានសុខាភិបាលស្ម័គ្រចិត្តទាំងសាធារណៈ និងឯកជនដែលអនុវត្តស្តង់ដារនៃការទទួលស្គាល់គុណភាពសេវាមន្ទីរពេទ្យ (CHAS) និង ស្តង់ដារនៃការទទួលស្គាល់គុណភាពមណ្ឌលសុខភាព(CHCAS)។

តាមរយៈគម្រោង H-EQIP II សម្រាប់គ្រប់មន្ទីរពេទ្យ និងមណ្ឌលសុខភាពទាំងអស់ដែលអនុវត្តស្តង់ដារនៃការទទួលស្គាល់គុណភាពសេវាមន្ទីរពេទ្យ និងមណ្ឌលសុខភាព។

ស្តង់ដារទាំងពីរនេះត្រូវសត្រាយផ្លូវដល់ថ្នាក់ដឹកនាំមន្ទីរពេទ្យ និងមណ្ឌលសុខភាពឱ្យជឿលើឥរិយាបទប្រកបដោយសីលធម៌របស់បុគ្គលិក និងលើកកម្ពស់វប្បធម៌គ្មានការស្តីបន្ទោសដើម្បីគុណភាព។

USAID FROM THE AMERICAN PEOPLE fhi360

# សង្ខេប CHAS

| ក្រុម # | ក្រុមស្តង់ដារ | ធាតុវាស់វែង | Critical | Core | Stretch | សរុប |
|---|---|---|---|---|---|---|
| 1 | សិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកជំងឺ និងក្រុមគ្រួសារ | 54 | 4 | 16 | 0 | 20 |
| 2 | ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង | 72 | 7 | 19 | 1 | 27 |
| 3 | ការលើកកម្ពស់គុណភាព សុវត្ថិភាពអ្នកជំងឺ និងការគ្រប់គ្រងហានិភ័យ | 46 | 2 | 7 | 5 | 14 |
| 4 | ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ | 134 | 17 | 16 | 2 | 35 |
| 5 | ការគ្រប់គ្រងធនធានមនុស្ស | 107 | 6 | 25 | 0 | 31 |
| 6 | ការថែទាំអ្នកជំងឺ | 172 | 30 | 29 | 0 | 59 |
| 7 | ការគ្រប់គ្រងឱសថ | 84 | 20 | 7 | 0 | 27 |
| 8 | សេវាធ្វើរោគវិនិច្ឆ័យ | 129 | 34 | 20 | 0 | 54 |
| 9 | សេវាគាំទ្រ | 106 | 9 | 16 | 2 | 27 |
| 10 | សុវត្ថិភាព និងសន្តិសុខបរិស្ថាន | 117 | 8 | 26 | 0 | 34 |
| 11 | ការគ្រប់គ្រងព័ត៌មានសុខាភិបាល | 113 | 4 | 27 | 6 | 37 |
| | សរុប | 1133 | 141 | 208 | 16 | 365 |

# សង្ខេប CHCAS

| ក្រុម # | ក្រុមស្តង់ដារ | ធាតុវាស់វែង | Critical | Core | Stretch | សរុប |
|---|---|---|---|---|---|---|
| 1 | សិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកជំងឺ និងក្រុមគ្រួសារ | 59 | 3 | 9 | 1 | 13 |
| 2 | គ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស | 41 | 5 | 6 | 0 | 11 |
| 3 | ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ | 39 | 9 | 1 | 1 | 11 |
| 4 | ការលើកកម្ពស់គុណភាព សុវត្ថិភាពអ្នកជំងឺ និងការគ្រប់គ្រងហានិភ័យ | 39 | 0 | 5 | 3 | 8 |
| 5 | ការគ្រប់គ្រងឱសថ | 19 | 5 | 1 | 0 | 6 |
| 6 | សេវាមន្ទីរពិសោធន៍ | 24 | 6 | 2 | 0 | 8 |
| 7 | ការថែទាំអ្នកជំងឺ | 43 | 8 | 4 | 0 | 12 |
| 8 | ការចូលរួមរបស់សហគមន៍ | 18 | 1 | 4 | 0 | 5 |
| 9 | បរិស្ថាន សុវត្ថិភាព និងសន្តិសុខ | 40 | 5 | 4 | 2 | 11 |
| 10 | ការគ្រប់គ្រងព័ត៌មានសុខាភិបាល | 36 | 2 | 12 | 3 | 17 |
| | សរុប | 358 | 44 | 48 | 10 | 102 |

# ការពង្រឹងឥរិយាបទសីលធម៌គិលានុបដ្ឋាកតាមរយៈការអនុវត្ត CHAS

| PFR.8 មន្ទីរពេទ្យជានាថាគណៈកម្មការក្រុមសីលធម៌ ( Ethics Committee ) បានពិនិត្យ និងអនុម័តិរាល់ពិធីសារស្រាវជ្រាវ ដែលពាក់ព័ន្ធនឹងមនុស្សដែលទាមទារដោយច្បាប់។ | ចំណាត់ថ្នាក់/ទម្ងន់នៃស្តង់ដារ<br>Critical |
|---|---|
| ធាតុវាស់វែង | |
| ១. ពិធីសារស្រាវជ្រាវ ដែលពាក់ព័ន្ធនឹងមនុស្ស ត្រូវបានពិនិត្យ និងអនុម័តិដោយគណៈកម្មការក្រុមសីលធម៌។<br>២. មានការអនុញ្ញាតជាលាយលក្ខ័ណ៍អក្សរដើម្បីធ្វើការស្រាវជ្រាវ។ | |

| PFR.9 ការផ្តល់ការថែទាំត្រូវធ្វើឡើងដោយយកចិត្តទុកដាក់ និងមានការគោរពគុណតម្លៃ (value) និងជំនឿ ឬសាសនារបស់អ្នកជំងឺ។ | ចំណាត់ថ្នាក់/ទម្ងន់នៃស្តង់ដារ<br>Critical |
|---|---|
| ធាតុវាស់វែង | |
| ១. មានគោលនយោបាយ និងនីតិវិធីពណ៌នាអំពីរបៀបដែលកំណត់ និងគោរពគុណតម្លៃ និងជំនឿ ឬសាសនា ដែលអាចអនុវត្តបានចំពោះក្រុមគ្រួសារ និងអ្នកជំងឺ។<br>២. បុគ្គលិកផ្តល់ការថែទាំដោយគោរពគុណតម្លៃ និងជំនឿ ឬសាសនារបស់អ្នកជំងឺ ស្របតាមគោលនយោបាយ និងនីតិវិធី។ | |

# ការពង្រឹងឥរិយាបទសីលធម៌គិលានុបដ្ឋាកតាមរយៈការអនុវត្ត CHAS

| | |
|---|---|
| **PFR.10** ការផ្តល់ការថែទាំត្រូវបានគោរពតាមតម្រូវការរបស់អ្នកជំងឺស្តីពីភាពឯកជន ជាពិសេសក្នុងអំឡុងពេលសម្ភាសគ្លីនិក ការពិនិត្យគ្លីនិក និង ទម្រង់ការ ឬការព្យាបាល។ | ចំណាត់ថ្នាក់/ទម្ងន់នៃស្តង់ដារ<br>Critical |
| ធាតុវាស់វែង | |
| ១. បុគ្គលិកកំណត់ពីការរំពឹងទុករបស់អ្នកជំងឺ និងតម្រូវការភាពឯកជនក្នុងអំឡុងពេលថែទាំ និង ព្យាបាល។<br>២. ភាពឯកជនរបស់អ្នកជំងឺត្រូវបានគោរពរាល់ការសម្ភាសគ្លីនិក ការពិនិត្យគ្លីនិក និងទម្រង់ការព្យាបាលទាំងអស់។<br>៣. ភាពឯកជនរបស់អ្នកជំងឺត្រូវបានរក្សាទុកទាំងព័ត៌មានដែលត្រូវបានប្រមូលនៅកន្លែងចុះឈ្មោះ កន្លែងផ្តល់ឱសថនៅឱសថស្ថាន និងទីតាំងផ្សេងទៀតដែលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកជំងឺត្រូវបានចែករំលែក។ | |

# ការពង្រឹងនីតិវិធីស្ដង់ដារក្នុងការវាយតម្លៃការអនុវត្ត CHAS

| MR.4 កំណត់ត្រាវេជ្ជសាស្ត្រត្រូវបានរៀបចំដើម្បីលើកកម្ពស់ការថែទាំជាបន្ត។ | ចំណាត់ថ្នាក់/ទម្ងន់នៃស្តង់ដារ<br>Critical |
| --- | --- |

**ធាតុវាស់វែង**

១. គោលនយោបាយនិងនីតិវិធីស្តីពីកំណត់ត្រាវេជ្ជសាស្ត្រ ចែងថាកំណត់ត្រាវេជ្ជសាស្ត្រនឹងមានផ្ទុករាល់សមាសធាតុទាំងអស់ដែលលើកកម្ពស់ការថែទាំជាបន្ត រួមទាំង

ក. ទម្រង់នៃការវាយតម្លៃពេញលេញ

ខ. ផែនការថែទាំត្រឹមត្រូវ

គ. សេចក្តីសង្ខេបពេញលេញនៃការផ្ទេរអ្នកជំងឺ

ឃ. របាយការណ៍វះកាត់

ង. កំណត់ត្រាគ្រូពេទ្យនៃការវិវត្តរបស់អ្នកជំងឺ

ច. សេចក្តីសង្ខេបអំពីការចេញពីពេទ្យ

២. កំណត់ត្រាអ្នកជំងឺម្នាក់ៗ ត្រូវបានរៀបចំទៅតាមគោលនយោបាយ និងនីតិវិធី។

| MR.5 កំណត់ត្រាវេជ្ជសាស្ត្រនីមួយៗ មានព័ត៌មានគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការធ្វើរោគវិនិច្ឆ័យ និងផ្តល់ជាហេតុផលសម្រាប់ការថែទាំ ការព្យាបាល និងសេវានានាដែលបានផ្តល់ ។ | ចំណាត់ថ្នាក់/ទម្ងន់នៃស្តង់ដារ<br>Critical |
| --- | --- |

**ធាតុវាស់វែង**

១. កំណត់ត្រាវេជ្ជសាស្ត្រមានព័ត៌មានដែលគាំទ្រដល់ការធ្វើរោគវិនិច្ឆ័យត្រឹមត្រូវ ដូចជាការសាកសួរប្រវត្តិនិងពិនិត្យរាងកាយ (H&P) ដោយគ្រូពេទ្យ លទ្ធផលនៃការអង្កេតស្រាវជ្រាវ ការរកឃើញពីការវះកាត់។ ល។

២. កំណត់ត្រាវេជ្ជសាស្ត្រមានព័ត៌មាន ដូចជា ការធ្វើរោគវិនិច្ឆ័យមុនពេលវះកាត់ ផែនការថែទាំ និងកំណត់ត្រាគ្រូពេទ្យនៃការវិវត្តរបស់អ្នកជំងឺ ដែលបញ្ជាក់អំពីហេតុផលនៃការព្យាបាល។

# ការពង្រឹងឥរិយាបទសីលធម៌គិលានុបដ្ឋាកតាមរយៈការអនុវត្ត CHAS

| **MR.9.1** ភាពជាឯកជន និងភាពសម្ងាត់នៃព័ត៌មានអ្នកជំងឺ ត្រូវបានការពារ។ | ចំណាត់ថ្នាក់/ទម្ងន់នៃស្តង់ដារ<br>Critical |
|---|---|

**ធាតុវាស់វែង**

១. គោលនយោបាយនិងនីតិវិធីស្តីពីឯកជនភាព និងភាពសម្ងាត់នៃព័ត៌មានរបស់អ្នកជំងឺ និងបុគ្គលដែលអាចចូលមើលកំណត់ត្រាវេជ្ជសាស្រ្ត ត្រូវបានសរសេរឡើង។

២. ព័ត៌មានមិនត្រូវបានផ្តល់ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកជំងឺ ឬដោយមានការលើកលែងមួយចំនួន ( ឧ. សេចក្តីបង្គាប់របស់តុលាការ ) ។

៣. គោលនយោបាយនិងនីតិវិធីនេះ កំណត់ពីកាលៈទេសៈណាខ្លះដែលសិទ្ធិចូលមើលកំណត់ត្រាត្រូវបានផ្តល់ និងដំណើរការសម្រាប់ការបញ្ចេញព័ត៌មានរបស់អ្នកជំងឺ។

USAID FROM THE AMERICAN PEOPLE fhi360

# សារគន្លឹះ

- អ្នកដែលចាប់អារម្មណ៍ប្រកបវិជ្ជាជីវៈសុខាភិបាលគឺពួកគាត់ចង់ជួយមនុស្ស តាមរយៈការព្យាបាល និងថែទាំប្រកបដោយសមធម៌ យុត្តិធម៌ ទៅតាមគុណតម្លៃ វប្បធម៌និងជំនឿផ្ទាល់ខ្លួនរបស់ពួកគាត់ ជាការល្អ ដោយគុណតម្លៃទាំងនោះត្រូវដាក់បញ្ចូលទៅក្នុងច្បាប់ ប្រកាស និងនិយាមនៃវិស័យសុខាភិបាលដើម្បីគាំទ្រដល់ជំនឿទាំងនោះ។
- យុទ្ធសាស្រ្តមួយក្នុងចំណោមយុទ្ធសាស្រ្តនៃការអនុវត្តដ៏សំខាន់បំផុតគឺថាថ្នាក់ដឹកនាំនៃមូលដ្ឋានសុខាភិបាលមានភាពជឿជាក់ និងមានឥរិយាបទប្រកបដោយសីលធម៌ដើម្បីជាគំរូ និងលើកកម្ពស់វប្បធម៌ដែលគ្មានការស្តីបន្ទោសដើម្បីលើកកម្ពស់គុណភាពសេវាថែទាំ សុវត្ថិភាពអ្នកជំងឺ ការថែទាំផ្តោតលើអតិថិជន និងប្រកបដោយវិជ្ជាជីវៈ។
- ឥរិយាបទប្រកបដោយសីលធម៌របស់អ្នកវិជ្ជាជីវៈសុខាភិបាលអាចត្រូវបានជំរុញតាមរយៈការអនុវត្ត ដែនកំណត់ និងនិយាមវិជ្ជាជីវៈ អនុក្រិត្យស្តីពីក្រមសីលធម៌ និង CHAS/CHCAS ។

# References


- Tafesse et al (2022). Clinical ethical practice and associated factors in healthcare facilities in Ethiopia: a cross-sectional study. Retrieved on Feb 17, 2024 @ https://bmcmedethics.biomedcentral.com/articles/10.1186/s12910-022-00800-0.
- Cambodian Hospital Accreditation Standards (MOH, 2022)

# សូមអរគុណ!

**FHI 360 Headquarters**

359 Blackwell Street, Suite 200, Durham, NC 27701 USA

www.fhi360.org